# ការតភ្ជាប់អាជ្ញាធរ និង សង្គមស៊ីវិល



*អំពើហឹង្សា និងការរំលោភបំពានលើកុមារមាននៅគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោក តាមរយៈ វប្បធម៌ ថ្នាក់សង្គម ការអប់រំ ប្រាក់ចំណូល និងប្រភពដើមនៃជាតិសាសន៍ ប្រទេសកម្ពុជា ក៏មិនខុសគ្នាដែរ។ ជាងពាក់កណ្តាលនៃចំនួនកុមារកម្ពុជា ត្រូវបានគេផ្តល់របាយការណ៍ថាទទួលរងអំពើហឹង្សាលើរាងកាយ មួយភាគបួននៃចំនួនកុមារកម្ពុជា ត្រូវបានរំលោភបំពានផ្លូវចិត្តនៅពេលដែលកំពុងធំធាត់ឡើង។ ប្រហែលជា៥%ក្នុងចំណោមស្រី និងប្រុសដែលមានអាយុចន្លោះពី ១៣ ទៅ ២៤ឆ្នាំ មានការរំលោភបំពានផ្លូវភេទមុនអាយុ ១៨ឆ្នាំ។[1] សកម្មភាពត្រូវការជាចាំបាច់ ហើយវាពិតជាមានការលើកទឹកចិត្តនៅពេលដែលឃើញប្រជាជននៅក្នុងសហគមន៍មូលដ្ឋាន កំពុងបង្កើនការការពារកុមារ។ អំណាចនៃការរួបរួមក្នុងបុព្វហេតុរួមក្នុងការការពារកុមារ មិនអាចមើលរំលងបានឡើយ។ ឧទាហរណ៍ប្រជាជនដែលកំពុងធ្វើការរួបរួមគ្នានោះគឺ គណៈកម្មាធិការការពារកុមារ (គកក) ដែលកុមារ យុវជនយុវនារី ឪពុកម្តាយ និងអ្នកដឹកនាំសាសនាបានរួមគ្នាធ្វើការ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានកុមារ និងការព្រងើយកណ្តើយ។*

គម្រោងអាយស៊ីស៊ី “សម្លេងនៃកុមារ”(វីអូធីស៊ី) ចាប់តាំងពីឆ្នាំ២០១២ បាននិងកំពុងធ្វើការដើម្បីបំពាក់បំប៉ន់ និងពង្រឹងសិទ្ធិអំណាចដល់អ្នកដឹកនាំក្រុមជំនុំគោលដៅទាក់ទងនឹងការការពារកុមារ និងសិទ្ធិកុមារ ហើយឥឡូវនេះ អ្នកដឹកនាំក្រុមជំនុំទាំងនេះបានត្រៀមខ្លួនរួចរាល់ ដើម្បីកេណ្ឌប្រមូលអ្នកភូមិ និងធនធានរបស់ពួកគាត់ ក្នុងកិច្ចការពារកុមារតាមរយៈ គកក។

វាជាបញ្ហាប្រឈមមួយក្នុងការផ្លាស់ប្តូរផ្នត់គំនិតចាស់ និងការអនុវត្តបែបប្រពៃណី ដូចគ្នាដែរទាក់ទងទៅនឹងការការពារកុមារ វាទាមទារពេលវេលា និងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន ឲ្យយល់ពីអំណាចនៃការរួបរួមធ្វើការជាមួយគ្នា ដើម្បីការពារកុមារ។ ដូច្នេះ វាជាការលើកទឹកចិត្តសម្រាប់ក្រុមការងាររបស់វីអូធីស៊ីដែលបានដឹងថា អ្នកដឹកនាំក្រុមជំនុំគោលដៅ មានបំណង់ចិត្ត និងទស្សនៈវិស័យក្នុងការបង្កើត គកក នៅក្នុងភូមិរបស់ពួកគាត់ផ្ទាល់។ អ្នកដឹកនាំក្រុមជំនុំទាំងនេះ មានលទ្ធិភាព ជ្រើសរើសសមាជិក គកក ដែលមានសមត្ថភាព និងមានការប្តេជ្ញាចិត្តពីភូមិរបស់ពួកគាត់ ក៏ប៉ុន្តែក្នុងពេលជាមួយគ្នានេះដែរ ពួកគាត់ត្រូវការការទទួលស្គាល់នៃ គកក ពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ដំបូងពួកគាត់ ត្រូវសុំការអនុញ្ញាត និងការគាំទ្រពីមេភូមិរបស់ពួកគាត់។ នេះ មិនមែនចេះតែងាយស្រួលនោះទេ ព្រោះមេភូមិទាំងអស់ មិនសុទ្ធតែគិតវិជ្ជមានអំពីតួនាទីរបស់ គកក។ អ្នកដឹកនាំក្រុមជំនុំមួយចំនួនត្រូវចំណាយពេលវេលា និងការចូលរួមច្រើន ដើម្បីអាចឲ្យមេភូមិមើលឃើញទិដ្ឋភាពធំនៃ គកក។ ក្រុមការងារវីអូធីស៊ី ជួយនិងគាំទ្រអ្នកដឹកនាំក្រុមជំនុំគោលដៅ ដើម្បីធ្វើឲ្យប្រាកដថា គកក នីមួយៗ បម្រើឧត្តមប្រយោជន៍ដល់កុមារ ហើយមេភូមិ នឹងគាំទ្រយ៉ាងសកម្ម។

ដំបូងឡើយ មេភូមិម្នាក់មានគំនិតអវិជ្ជមានយ៉ាងខ្លាំងពីផែនការនៃ គកក នៅក្នុងភូមិរបស់គាត់។ គាត់បានមានប្រសាសន៍ថា វាមិនអាចទៅរួចទេសម្រាប់អ្នកភូមិក្នុងការចំណាយពេល និងធនធានផ្ទាល់ខ្លួនរបស់គាត់ដែលជាផ្នែកមួយនៃ គកក។ លោកក៏បានបញ្ជាក់ផងដែរថា អ្នកភូមិ នឹងមិនចូលរួមជាមួយ គកក នេះទេ លុះត្រាណាពួកគេទទួលបានអត្ថប្រយោជន៍មួយចំនួនមកវិញ។ ទោះជាយ៉ាងណាក៏ដោយ អ្នកដឹកនាំក្រុមជំនុំម្នាក់នៅក្នុងភូមិនេះ មិនចង់បោះបង់ផែនការ គកក របស់គាត់ទេ។ ផ្ទុយទៅវិញ គាត់ បានអញ្ជើញមេភូមិឲ្យចូលរួមកិច្ចប្រជុំ គកក។ កិច្ចប្រជុំ បានជួយមេភូមិ យល់ពីមូលហេតុដែលចាំបាច់ត្រូវមាន គកក នៅក្នុងភូមិ បន្ទាប់មកគាត់បានចាប់ផ្តើមផ្លាស់ប្តូរការគិតរបៀបចាស់អំពីអ្នកភូមិរបស់គាត់ ហើយចាប់ផ្តើមមានភាពសកម្មជាងមុនដើម្បីគាំទ្រផែនការ គកក។

ឥឡូវនេះ មេភូមិម្នាក់នេះមានមោទនភាពចំពោះ គកក ហើយជាញឹកញាប់ គាត់តែងតែរាយការណ៍ និងចែករំលែកអំពីសកម្មភាពរបស់ គកក ទៅកាន់អាជ្ញាធរមូលដ្ឋាននៅថ្នាក់ឃុំ និងក្នុងកិច្ចប្រជុំឃុំ/សង្កាត់ប្រចាំត្រីមាស។ គាត់ បន្តចែករំលែកអំពីបទពិសោធរបស់គាត់ជាមួយនឹង គកក គាត់បានជម្រុញទឹកចិត្ត និងលើកទឹកចិត្តមេភូមិ និងមេឃុំផ្សេងទៀតឲ្យគាំទ្រ គកក តួនាទី និងដំណើរការក្នុងភូមិ និងឃុំ។ ជាលទ្ធផល មាន គកក ចំនួន១០ ដែលបានបង្កើតឡើងនៅក្នុងខេត្តតាកែវដែលត្រូវបានអនុម័តជាផ្លូវការតាមរយៈការចុះហត្ថលេខារបស់មេភូមិ និងមេឃុំក្នុងអំឡុងពេលពិធីមួយ-ដូចដែលបានឃើញនៅក្នុងរូបភាពខាងលើ។

---

[1] The Economic Burden of the Health Consequences of Violence Against Children in Cambodia (year 2014)